ធ៧-០៣-០១ ស.រ.ណ.ន

# សារាចរណែនាំ
# ស្តីពី
# ការធ្វើបង្គរ និងរំលស់ប្រចាំថ្ងៃសម្រាប់
# ធនាគារពាណិជ្ជ និងធនាគារឯកទេស

មូលដ្ឋានសម្រាប់កត់ត្រាគណនេយ្យ ត្រូវបានទទួលស្គាល់ជាមធ្យោបាយមួយសម្រាប់ផ្តល់ព័ត៌មាន ដែលមានប្រយោជន៍ត្រឹមត្រូវ និងទាន់ពេលវេលាទៅគ្រប់អ្នកប្រើប្រាស់ដែលត្រូវការ។ ហេតុនេះ ដើម្បីសំរួលដល់ដំណើរការប្រើប្រាស់ប្រព័ន្ធគណនេយ្យបង្គរ និងការត្រួតពិនិត្យទិន្នន័យ ផ្តល់មូលដ្ឋានប្រព័ន្ធគ្រប់គ្រងព័ត៌មានកាន់តែប្រសើរឡើងដល់ធនាគារិក ពិសេសការអនុវត្តន៍ប្លង់គណនីឯកភាពប្រព្រឹត្តទៅបានល្អ និងមានតម្លាភាព ធនាគារជាតិនៃកម្ពុជា កំណត់ដូចខាងក្រោម:

១. គ្រប់ធនាគារពាណិជ្ជនិងធនាគារឯកទេស ត្រូវគណនា និងចុះបញ្ជិកាបង្គរការប្រាក់ និងរំលស់លើអចលនទ្រព្យរៀងរាល់ថ្ងៃ

២. ការធ្វើបង្គរ និងរំលស់ប្រចាំថ្ងៃ ត្រូវបានគិតបញ្ចូលសម្រាប់ការអនុវត្តប្លង់គណនីពេញលេញ

សារាចរណែនាំនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៣

**នាយកដ្ឋានត្រួតពិនិត្យ**

**ផាន់ ហូរ   នាង ច័ន្ទថាណា**